# ប្រជុំប្រចាំឆ្នាំ ២០០៨ របស់អង្គការសេដាក និងសដៅឆ្នាំ ២០០៩-២០១១

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) បានប្រារព្ធការប្រជុំប្រចាំឆ្នាំ ២០០៨ របស់ខ្លួនរយៈពេលពីរថ្ងៃ នៅថ្ងៃទី ៣០-៣១ ខែធ្នូ ឆ្នាំ ២០០៨ នៅសាលប្រជុំមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) ។ អង្គប្រជុំនេះមានអ្នកចូលរួមសរុបប្រមាណ ២៣៩ នាក់ ដែលជាបុគ្គលិកសេដាក តំណាងបណ្តាញកសិករនិងធម្មជាតិ តំណាងកសិករ សិស្សអ្នកដឹកនាំវ័យក្មេង ជំនួយការតាមមូលដ្ឋាន និងសមាជិកក្រុមប្រឹក្សាភិបាលអង្គការសេដាក។ កិច្ចប្រជុំនេះសម្រេសសម្រួលរួមដោយ លោកតាត់ សុខ, លោកឃឹម សុផាណ្ណា, លោកប្រាក់ សេរីវឌ្ឍន៍, អ្នកស្រីតុង ចាន់ធាង កញ្ញា សយ សុភ័ក្ត្រា និងកញ្ញា លុយ ធារី។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំនងបង្ហាញលទ្ធផលការងារឆ្នាំ ២០០៨ របស់ផ្នែកនីមួយៗ ក៏ដូចជាបង្ហាញពីយុទ្ធសាស្ត្រសម្រាប់សេដាកឆ្នាំ ២០០៩-២០១១។ នៅក្នុងអង្គប្រជុំរយៈពេលពីរថ្ងៃ អ្នកចូលរួមទាំងអស់បានស្តាប់របាយការណ៍ លទ្ធផលការងារឆ្នាំ ២០០៨ របស់ផ្នែកនីមួយៗរបស់អង្គការសេដាក រួមទាំងចំណាប់អារម្មណ៍របស់បុគ្គលិកនៅតាមផ្នែក, តំណាងសមាជិកក្រុមប្រឹក្សាភិបាលអង្គការសេដាក, តំណាងកសិករទទួលផល និងសិស្សអ្នកដឹកនាំវ័យក្មេង ក៏ដូចជាជំនួយការតាមមូលដ្ឋាន ដែលពួកគាត់បានចែករំលែកជុំវិញការរីកចំរើនផ្ទាល់ខ្លួន និងនៅក្នុងសហគមន៍ទាំងមូល ដោយបានធ្វើកាសហការជាមួយអង្គការសេដាកក្នុងរយៈពេលមួយឆ្នាំ ២០០៨ កន្លងទៅនេះ។ នៅថ្ងៃទីពីរ អង្គប្រជុំក៏បានធ្វើបទបង្ហាញពីយុទ្ធសាស្ត្រសម្រាប់សេដាកឆ្នាំ ២០០៩-២០១១ ដោយបណ្ឌិតយ៉ង សាំងកុមារ ប្រធានអង្គការសេដាក និងទស្សនាខ្សែវីដេអូស្តីអំពីសកម្មភាពអភិវឌ្ឍន៍សង្ខេបរបស់អង្គការសេដាក ហើយនៅពេលរសៀលបានបោះឆ្នោតជ្រើសរើសបុគ្គលិកឆ្នើមប្រចាំឆ្នាំ និងប្រុសស្អាត ស្រីស្អាតផងដែរ។ ក្រោយពេលបញ្ចប់កិច្ចប្រជុំ អង្គប្រជុំទាំងអស់ក៏បានពិសារអាហាររួមគ្នានៅការិយាល័យកណ្តាលអង្គការសេដាកផងដែរ។